# មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ

## ១.ស្ថានភាពទូទៅ

*មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ សរសេរអក្សរកាត់ ម ស វ វ មានឋានៈស្មើនាយកដ្ឋាន ស្ថិតនៅក្រោមការគ្រប់គ្រងនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈជាគ្រឹះស្ថានរដ្ឋបាលសាធារណៈ ក្រោម អាណាព្យាបាលក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។*

*មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌ បច្ចុប្បន្ន បាននឹងកំពុងដំណើរការ ស្រាវជ្រាវ ប្រមែប្រមូល និងចងក្រងឯកសារទាក់ទងនឹង ប្រពៃណី សិល្បៈវប្បធម៌ រូបបីនិងអរូបី ដូចជា ភ្លេង របាំ ល្ខោន គំនូរ ចម្លាក់ ប្រវត្តិសំណង់បុរាណប្រាសាទ ការចុះកម្មសិក្សា និងសកម្មភាពនានារបស់ សាស្ត្រាចារ្យ និស្សិតនៅតាមមហាវិទ្យាល័យនីមួយៗរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។*

*មជ្ឈមណ្ឌលនេះបន្ទុំទៅដោយអ្នកស្រាវជ្រាវ ដែលមានជំនាញ ផ្នែកតូរ្យតន្ត្រី សិល្បៈនាដសាស្ត្រ បុរាណវិទ្យា សិល្បៈសូនរូប និង ស្ថាបត្យកម្មនិងនគរោបនីយវិទ្យា ។ សព្វថ្ងៃនេះមជ្ឈមណ្ឌលកំពុងសហ-ការស្រាវជ្រាវជាមួយ មហាវិទ្យាល័យទាំង៥ របស់សាកលវិទ្យាល័យដើម្បី ប្រមែប្រមូលពត៌មាននានាទាក់ទងនឹងប្រវត្តិ ក៏ដូចសកម្មភាពរបស់មហាវិទ្យាល័យដើម្បី បោះពុម្ពផ្សាយជាទស្សនាវដ្តីប្រចាំឆ្នាំ ។*

*បច្ចុប្បន្នមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ បានប្រែមុខមាត់ ពីដំណើរការយឺតៗ មកមានសន្ទុះគួរឲ្យកត់សម្គាល់ អាស្រ័យដោយមានការយកចិត្តទុកដាក់ពី ថ្នាក់ដឹកនាំក្រសួងវប្បធម៌ ជាពិសេសពីសំណាក់ឯកឧត្តមសាកលវិទ្យាធិការផ្ទាល់ ក្នុងការជំរុញ ឲ្យមានល្បឿន ក្នុងការអភិវឌ្ឍ នៃមជ្ឈមណ្ឌលស្រាវជ្រាវនេះ ទាំងថវិកានិងស្មារតី ។*

## ២.ប្រវត្តិសង្ខេបរបស់មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ

*មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌ បង្កើតឡើងដើម្បីប្រមូលចងក្រងផ្សព្វផ្សាយនូវអ្វី ដែលបានបាត់បង់ ទាំងផ្នែកឯកសារអាន សម្ភារៈខាងសិល្បៈ ដើម្បីចងក្រងជាសៀវភៅទាំងទ្រឹស្តី និងបច្ចេកទេស សម្រាប់បំរើឲ្យវិស័យវប្បធម៌សិល្បៈ ឲ្យរស់ឡើងវិញ ក្រោយពីត្រូវរបបប្រល័យពូជសាសន៍ ប៉ុលពត កំទេចចោលគ្មានសល់ ។*

*ដំបូងមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌ ជាការិយាល័យស្រាវជ្រាវវប្បធម៌ បង្កើតឡើងនៅឆ្នាំ ១៩៨១ ដល់ ១៩៨៥ មានទីតាំងនៅមុខវត្តកោះ ក្នុងបំណងប្រមូលចងក្រងឯកសារដែលសេសសល់ពីសម័យប៉ុលពត ក្រោមគំនិតផ្តួចផ្តើមនិងចង្អុលបង្ហាញរបស់លោករដ្ឋមន្ត្រី* **ឆេង ផុន** *បន្ទាប់មកលោករដ្ឋមន្ត្រី* ***ហង្ស ជួន*** *ដែលបានដឹកនាំនាពេលនោះ ហើយបានប្រគល់ភារកិច្ចជូនលោកសាស្ត្រាចារ្យ* **យី ធន** *ជាប្រធានដឹកនាំការិយាល័យស្រាវជ្រាវវប្បធម៌ព្រមទាំងសាស្ត្រាចារ្យដទៃទៀត ។*

*នៅឆ្នាំ១៩៨៦ ដល់ឆ្នាំ ១៩៩៣ ការិយាល័យស្រាវជ្រាវវប្បធម៌ ត្រូវបានរើទៅការិយាល័យថ្មីនៅអតីតសាលា* ***ឋាច់ ជា*** *(ខាងលិចស្តាតចាស់) ស្ថិតក្រោមការគ្រប់គ្រងរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលដឹកនាំដោយ ឯកឧត្តម* ***ប៉ែន យ៉េត*** *និងឯកឧត្តម* ***ស៊ិក ប៊ុនហុក*** *។*

*នៅឆ្នាំ១៩៩៤ ក្រោមការដឹកនាំដោយផ្ទាល់របស់ ឯកឧត្តម* **នុត ណារាំង** *អតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានប្រែក្លាយការិយាល័យស្រាវជ្រាវវប្បធម៌ ទៅជា មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ ឋានៈស្មើនាយកដ្ឋាន ។ ក្រោយមកភារកិច្ចនេះបានប្រគល់ជូនលោកសាស្ត្រាចារ្យ* ***ឡោ សាន*** *ជាប្រធានមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ និងថ្នាក់ដឹកនាំដទៃទៀត ដូចជាលោកសាស្ត្រាចារ្យ* ***ប៉ោ ទៀង*** *លោកសាស្ត្រាចារ្យ* ***សាន ស៊ីសាមុត*** *ជាដើម ដែលបានខិតខំប្រឹងប្រែង ប្រមូលចងក្រង ដាវីដេអូ ចម្រៀង បាសាក់ យីកេ មហោរី ពិណពាទ្យ និងសៀវភៅជាឯកសារមូលដ្ឋានសម្រាប់បង្រៀននិងរៀន ដល់សិស្ស និស្សិតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។*

នៅឆ្នាំ២០០០ ដល់ឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានតែងតាំងលោកសាស្ត្រាចារ្យ **ម៉ៅ ងីហុង** ជាប្រធាន និងលោកសាស្ត្រាចារ្យ **អន បញ្ញា** ជាអនុប្រធាន ដឹកនាំមជ្ឈមណ្ឌលនេះ ក្រោយពេលលោកសាស្ត្រាចារ្យមុនៗបានចូលនិវត្ត ។

ចាប់ពីឆ្នាំ ២០០៥ ដល់បច្ចុប្បន្ន លោកសាស្ត្រាចារ្យ **អន បញ្ញា** ជាអនុប្រធាន ត្រូវបានថ្នាក់ដឹកនាំរដ្ឋាភិបាលតែងតាំងជា **ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ** ក្រោយពេលលោក **ម៉ៅ ងីហុង**ឡើងតួនាទី ជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដើម្បីទទួលខុសត្រូវ ក្នុងការចងក្រងឯកសារជាវីដេអូ សៀវភៅ និងទស្សនាវដ្ដី ដើម្បីបម្រើឲ្យសេចក្ដីត្រូវការ របស់សិស្ស និស្សិត សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក៏ដូចជា សិស្ស និស្សិតគ្រប់មជ្ឈដ្ឋាន ដែលស្នេហាវិស័យសិល្បៈវប្បធម៌ ក្នុងការលើកស្ទួយមរតកជាតិ ។

## ៣.ថ្នាក់ដឹកនាំរបស់មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ



លោក ជី រដ្ឋា

ប្រធានមជ្ឈមណ្ឌល

បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកបុរាណវិទ្យា

ទូរស័ព្ទ ០១២ ៦៣៦ ០២៨ អ៊ីមែល rothachy@yahoo.com



លោក កុលសារូ

អនុប្រធានមជ្ឈមណ្ឌល

បរិញ្ញាបត្រជាន់ខ្ពស់រដ្ឋបាលសាធារណៈ

ទូរស័ព្ទ ០១២ ៧២ ៩៨ ០០ អ៊ីមែល kolsarou@gmail.com



លោក លី ជុយ

អនុប្រធានមជ្ឈមណ្ឌល

បរិញ្ញាបត្រសិល្បៈសូនរូប

ទូរស័ព្ទ ០១២ ៨៦ ៨៥ ៨៧ អ៊ីមែល lychuy168@gmail.com



លោក ហុង សិលា

នុប្រធានមជ្ឈមណ្ឌល

រិញ្ញាបត្រស្ថាបត្យកម្មនិងនគរូបនីយវិទ្យា

រស័ព្ទ ០១២ ៣១ ៦៦ ៧៧ អ៊ីមែល joe_art5@yahoo.com



លោក យ៉ា ដា

អនុប្រធានមជ្ឈមណ្ឌល

បរិញ្ញាបត្រជាន់ខ្ពស់បុរាណវិទ្យា

ទូរស័ព្ទ ០១១ ៩០៦ ២៥៩ អ៊ីមែល yadarufa@yahoo.com



លោកស្រី វ៉ា បុប្ផារី

ប្រធានការិយាល័យរដ្ឋបាល

បរិញ្ញាបត្រជាន់ខ្ពស់តន្ត្រីវិទ្យា

ទូរស័ព្ទ ០១៧ ៥២ ៣៩ ៧៩ អ៊ីមែល bopharyva@yahoo.com



លោក ទិត្យ ណារិទ្ធិ

ប្រធានការិយាល័យស្រាវជ្រាវវប្បធម៌រូបីនិងអរូបី

បរិញ្ញាបត្រជាន់ខ្ពស់រដ្ឋបាលសាធារណៈ

ទូរស័ព្ទ ០៩៩ ៩៩ ៦៨ ៩៦ អ៊ីមែល power011981@gmail.com



លោកស្រី ស៊ូ វណ្ណថា

មន្ត្រីមជ្ឈមណ្ឌល

បរិញ្ញាបត្រសិល្បៈនាដសាស្ត្រ

លេខទូរស័ព្ទ ០៧៧ ៤៦ ៤៤ ៤៦ អ៊ីមែល vantha@gmail.com



លោកស្រី ឃុល ទិត្យចិន្តា

មន្ត្រីមជ្ឈមណ្ឌល

បរិញ្ញាបត្រសិល្បៈនាដសាស្ត្រ

ទូរស័ព្ទ ០១២ ២៣ ០០ ៩៩អ៊ីមែល chenda_tith2002@yahoo.com



លោកហេង រ៉ាវុធ

មន្ត្រីមជ្ឈមណ្ឌល

បរិញ្ញាបត្រសិល្បៈសូនរូប

ទូរស័ព្ទ ០៩៧ ៩៧ ៧៩ ៦៨១  អ៊ីមែលmorkorkorravuth@gmail.com



លោក ង៉ួន មុនីសត្យា

មន្ត្រីមជ្ឈមណ្ឌល

បរិញ្ញាបត្រស្ថាបត្យកម្មនិងនគរោបនីយវិទ្យា

លេខទូរស័ព្ទ ០៩២ ៣៣ ៣៦ ២៧

## រចនាសម្ព័ន្ធមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ

# ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ



លោក អន បញ្ញា

**អនុប្រធាន**



លោក លី ផុយ



លោក កុល សារូ



លោក ហុង សិលា



លោក យ៉ាដា



លោកស្រី វ៉ា បុប្ផារី

ប្រធានការិយាល័យរដ្ឋបាល



លោក ទិត្យ ណារិទ្ធិ

ប្រធាន ការិយាល័យស្រាវជ្រាវ

## មន្ត្រីមជ្ឈមណ្ឌលស្រាវជ្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ


លោកស្រី ឃុប ទត្យចិន្តា


លោកស្រី សូ វណ្ណថា


លោក ឈួន មុនសត្យា


លោក ហេង រាវុធ

## ៧. កិច្ចសហការជាមួយស្ថាប័ននានា

**កិច្ចសហការទី១**

មជ្ឈមណ្ឌលបានសហការជាមួយលោកសាស្ត្រាចារ្យមកពីមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ ជំនាញរបាំបុរាណខ្មែរស្រាវជ្រាវចងក្រងឡើងវិញនូវ **លំហាត់ច្បាតរបាំក្បាច់បុរាណខ្មែរ** ភាគ I នឹងបន្តការស្រាវជ្រាវភាគ II នាឆ្នាំ២០១៥-២០១៦។

**កិច្ចសហការទី២**

មជ្ឈមណ្ឌលសហការជាមួយថ្នាក់ដឹកនាំមហាវិទ្យាល័យទាំង៥ និងសាស្ត្រាចារ្យជំនាញក្នុងគម្រោងផ្សព្វផ្សាយ ទស្សនាវដ្ដី នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ អំពីប្រវត្តិ កម្មវិធីសិក្សា និងសកម្មភាពជំនាញ ។ល។

**កិច្ចសហការទី៣**

ជាគម្រោងសិក្សាស្រាវជ្រាវបទភ្លេងនិងចម្រៀងអារក្សនៅខេត្តកំពង់ស្ពឺ តាកែវ និងខេត្តកែប ដែលសហការជាមួយនឹងប្រធានមន្ទីរវប្បធម៌ខេត្តទាំង៣។

**កិច្ចសហការទី៤**

ជាកិច្ចសហការជាមួយនឹងសាស្ត្រាចារ្យមហាវិទ្យាល័យតន្ត្រី លើគម្រោងស្រាវជ្រាវចងក្រងឧបករណ៍ពិណខ្មែរ ។

## ៨. លទ្ធផលដែលសម្រេចបាននិងផែនការស្រាវជ្រាវបន្ត

*លទ្ធផលដែលយើងសម្រេចបាន ក្នុងឆ្នាំចុងក្រោយនេះ គឺសៀវភៅ លំហាត់បាតរបាំក្បាច់បុរាណខ្មែរ ជាសៀវភៅមានសារៈសំខាន់ សម្រាប់ប្រជាជាតិខ្មែរគ្រប់រូប ព្រោះសៀវភៅនេះជារូបមន្តនៃក្បាច់របាំបុរាណខ្មែរ ដែលគាត់អាចស្វែងយល់រៀនសូត្រតាមរយៈសៀវភៅនេះដោយខ្លួនឯងបាន ។*

*នៅឆ្នាំសិក្សា២០១៥-២០១៦ នេះមជ្ឈមណ្ឌលមានគម្រោងស្រាវជ្រាវ ចំនួន០២ ទៀត*

*១ បទភ្លេងអារក្ស*

*២ ឧបករណ៍ពិណ*

*មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្របានសហការជាមួយមហាវិទ្យាល័យទាំង ៥ នៅក្នុងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដូចជា ៖*

*១ មហាវិទ្យាល័យតូរ្យតន្ត្រី*

*២ មហាវិទ្យាល័យសិល្បៈនាដសាស្ត្រ*

*៣ មហាវិទ្យាល័យបុរាណវិទ្យា*

*៤ មហាវិទ្យាល័យស្ថាបត្យកម្មនិងនគរូបនីយវិទ្យា*

*៥ មហាវិទ្យាល័យសិល្បៈសូនរូប*

*ដើម្បីសិក្សាស្រាវជ្រាវចងក្រងលើទម្រង់សិល្បៈ គ្រប់ជំនាញ ទុកជាឯកសារសម្រាប់សិស្សនិស្សិត និងអ្នកស្រាវជ្រាវបន្តបន្ទាប់ទៀត ។*

## ១០. រូបភាពពីសកម្មភាពរបស់មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ

*មន្ត្រីមជ្ឈមណ្ឌលប្រជុំពិភាក្សាជាមួយលោកសាស្ត្រាចារ្យ* **ព្រឿង ឈៀង** *និង លោកស្រី សាស្ត្រាចារ្យ* **ហ៊ឹម ណាឡា** *អំពីលំហាត់បាតក្បាច់របាំបុរាណខ្មែរ ។*









មន្ត្រីមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រចូលរួមកម្មវិធីផ្លាស់ប្តូរវប្បធម៌ អាស៊ាន ចិននៅព្រះរាជាណាចក្រថៃ និងនៅប្រទេសចិន នាថ្ងៃទី១៥-២៩ កុម្ភៈ ឆ្នាំ២០១២













